# សុន្ទរកថា
# ឯកឧត្តម ប្រាក់ សុខុន
# ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំ និងមន្ត្រី ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០២៣

--------------------------------

- ឯកឧត្តម សុខ ចិន្ដាសោភា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- ឯកឧត្តម លោកជំទាវ ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី សមាជិកព្រឹទ្ធសភា-រដ្ឋសភា ថ្នាក់ដឹកនាំ មន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាទីមេត្រី

១. ពីម្សិលមិញ រដ្ឋសភាជាតិបានបោះឆ្នោតផ្តល់សេចក្តីទុកចិត្តដល់គណៈរដ្ឋមន្ត្រីថ្មី ភាគច្រើនជាឥស្សរជនវ័យក្មេង ដែលបានទទួលការបណ្តុះបណ្តាលថ្នាក់ខ្ពស់ ហ្វឹកហាត់ការងារត្រឹមត្រូវ និងប្រកបទៅដោយមនសិការស្នេហាជាតិដ៏ជ្រាលជ្រៅ។ ថ្ងៃនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអញ្ជើញចូលកាន់តំណែងជារដ្ឋមន្ត្រីដឹកនាំក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដែលជាក្រសួងប្រកបដោយកិត្យានុភាព ព្រមជាមួយការប្រឈមជាយុទ្ធសាស្ត្រដ៏ពិបាក និងស្មុគ្រស្មាញ។

២. ពិធីផ្ទេរតំណែងថ្ងៃនេះ ត្រូវបានរំពឹង និងប្រុងប្រៀបទុកជាមុនច្រើនខែមកហើយ ដោយសារតែការផ្លាស់ប្តូរអំណាចថ្នាក់កំពូលត្រូវបានគិតគូរ រៀបចំផ្លូវផ្តងយ៉ាងហ្មត់ចត់យូរក្រៃលដែរ។ ប្រមាណជា ១៥ឆ្នាំមុន មិត្តដ៏ជិតស្និទ្ធរបស់ខ្ញុំម្នាក់បានពោលប្រាប់ខ្ញុំ ពេលដែលឪពុកជាទីស្រលាញ់របស់គាត់បានចាកផុតទៅ ក្រោយមានជម្ងឺជាយូរមកហើយ ថា៖ «ខ្ញុំបានត្រៀមចិត្ត

យូរហើយ ប៉ុន្តែលុះពេលវេលាមកដល់ ខ្ញុំពិបាកធ្វើអារម្មណ៍ឲ្យស្ងប់ណាស់!»។ ថ្ងៃនេះ យើងមិនមានបាត់បង់នរណាទេ ប៉ុន្តែខ្ញុំក៏ត្រូវទទួលស្គាល់ដែរថា ដូចក្នុងករណីរបស់មិត្តខ្ញុំដែរ នេះជាពេលវេលាដ៏រំជួលចិត្តបំផុតមួយសម្រាប់ខ្ញុំផ្ទាល់ ក្នុងរយៈពេលជាង ៤៤ឆ្នាំ ដែលខ្ញុំធ្វើការជូនរដ្ឋ និងក្រោយ ៧ឆ្នាំ ជារដ្ឋមន្ត្រីការបរទេស។

ឯកឧត្តម លោកជំទាវ
អស់លោក លោកស្រី,

៣. វាជាច្បាប់ធម្មជាតិដែលអ្វីៗតែងតែមានការចាប់ផ្តើម និងការបញ្ចប់ទៅវិញ។ ជាកិត្តិយសខ្ពង់ខ្ពស់ណាស់ដែល **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រគល់ឲ្យខ្លួនខ្ញុំនូវបេសកកម្មដ៏ថ្លៃថ្នូរបំផុត ក្នុងការការពារផលប្រយោជន៍ជាតិ និងប្រជាជនយើង លើសមរភូមិការទូតនានានៅក្នុងតំបន់ និងពិភពលោក។ តបទៅនឹងសេចក្តីទុកចិត្តដ៏ឧត្តុង្គឧត្តមរបស់**សម្តេចតេជោ** ខ្ញុំបានបម្រើ និងបំពេញបេសកកម្មនេះ ដោយស្មោះត្រង់បំផុតចំពោះជាតិ ដោយសេចក្តីថ្លៃថ្នូររបស់ខ្លួនឯងផង ការពារសេចក្តីថ្លៃថ្នូររបស់ជាតិផង និងដោយប្រកាន់នូវវិជ្ជាជីវៈខ្ពស់បំផុត ដែលខ្ញុំអាចធ្វើទៅបាន។ ខ្ញុំបានសន្យាចំពោះ **សម្តេចតេជោ** នាថ្ងៃចូលកាន់តំណែង គឺនៅថ្ងៃទី**៥ ខែមេសា ឆ្នាំ២០១៦**នោះថា ខ្ញុំនឹងខិតខំធានានិរន្តរភាពក្នុងការអនុវត្តនយោបាយការបរទេស និងការពារផលប្រយោជន៍គោលរបស់ជាតិ និងប្រជានជនយើង និងជំរុញកំណែទម្រង់នានាទៅតាមការចាំបាច់ និងស្របតាមការប្រែប្រួលយុទ្ធសាស្ត្រ និងភូមិសាស្ត្រនយោបាយក្នុងតំបន់ និងពិភពលោក។

**ការពិត កំណែទម្រង់ដែលចាំបាច់នោះ មានច្រើន។**

៤. <u>**លើផ្នែកសម្ភារៈ**</u> អាទិភាពដំបូង គឺការរៀបចំលក្ខខណ្ឌការងារឲ្យបានប្រសើរបំផុត។ ការយកចិត្តទុកដាក់ដំបូងបានផ្តោតទៅលើការបង្កនូវបរិស្ថានការងារ

អំណោយផល គឺរៀបចំទីកន្លែងសមរម្យបំផុតសម្រាប់មន្ត្រីយើងធ្វើការ ដោយជួសជុលកែលម្អអគារធំ បន្ថែមអគារថ្មី ផ្តល់មធ្យោបាយការងារចាំបាច់គ្រប់គ្រាន់ ដើម្បីបង្កើនប្រសិទ្ធិភាព គិតចាប់ពីការរៀបចំបន្ទប់ធ្វើការស្អាត បន្ទប់ទឹកស្អាត បំពាក់សម្ភារៈថ្មី និងជានាសេវាអ៊ីនធឺណែតខ្លាំង ជាដើម។ ជ្រុងមួយទៀត គឺការបង្កើតរបបប្រាក់រង្វាន់ ប្រាក់ឧបត្ថម្ភ តាមរយៈនៃការបង់ចំណូលចូលរដ្ឋត្រឹមត្រូវតាមច្បាប់ និងបង្កើនរបបប្រាក់បៀវត្ស ឈ្នួលផ្ទះ ថវិកាចំណាយរបស់ស្ថានបេសកកម្ម ដើម្បីសម្រាលការលំបាករបស់មន្ត្រីយើងទាំងក្នុង និងក្រៅប្រទេស និងឲ្យបានសមរម្យទៅនឹងតម្លៃនៃការរស់នៅ។

៥. **លើផ្នែកស្មារតី៖** ពីដំបូងទី យើងបានដាក់ឲ្យអនុវត្តប្រព័ន្ធគុណាធិបតេយ្យ ដើម្បីជានាសមភាពក្នុងការរៀបចំ តែងតាំង ផ្លាស់ប្តូរ និងតម្លើងឋានៈ និងប្រសិទ្ធិភាពការងារដោយយកលទ្ធផលជារង្វាស់។ អ្វីៗគ្រប់យ៉ាងត្រូវបានលើកទឹកចិត្ត ដើម្បីបង្កើតស្មារតីជាក្រុម «Team Spirit» ផ្តល់មោទនភាពក្នុងការបម្រើក្រសួងដ៏សំខាន់នេះ បង្កឡើងនូវសាមគ្គីភាព និងភាតរភាព។

៦. **លើផ្នែកវិជ្ជាជីវៈ៖** ការបង្កើតវិទ្យាស្ថានជាតិការទូត និងទំនាក់ទំនងអន្តរជាតិ ដែលជាវិទ្យាស្ថានដំបូងបំផុតរបស់ក្រសួងការបរទេស បានរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ការយល់ដឹង វិជ្ជាជីវៈ និងក្រមសីលធម៌នៃអ្នកការទូតរបស់យើង ក៏ដូចជាមន្ត្រីនៃក្រសួង-ស្ថាប័នពាក់ព័ន្ធនានា។ កិច្ចប្រជុំចែករំលែកព័ត៌មាន និងវិភាគសភាពការណ៍ ២ដង ក្នុងមួយសប្តាហ៍ ការវិភាគនានារបស់ក្រុមស្រាវជ្រាវ វិភាគ និងព្យាករណ៍ (IRAG) រួមជាមួយវិទ្យាស្ថានចក្ខុវិស័យអាស៊ី (AVI) ការចែករំលែកមតិ អត្ថាធិប្បាយ ក្នុងក្រុម Telegram របស់ថ្នាក់ដឹកនាំ និងប្រធានស្ថានបេសកកម្មនានា ការរៀបចំ Matrix ប្រៀបធៀប និងកំណត់ជំហររបស់យើងចំពោះបញ្ហាក្តៅៗក្នុងតំបន់ និងសកលលោក ទាំងអស់នេះបានផ្តល់នូវធាតុចូលដ៏សំខាន់ និងស៊ីជម្រៅដល់ការពិចារណារបស់មន្ត្រីយើងទាំងតូចទាំងធំ ជារៀងរាល់ថ្ងៃ។ ព្រមជាមួយយន្តការទំនាក់ទំនងសំបូរបែបនេះ ទូរស័ព្ទរបស់ខ្ញុំផ្ទាល់ត្រូវបានបើក

ទូលាយសម្រាប់ការឆ្លើយឆ្លង ការសុំយោបល់ មតិសម្រេច និងចំណាត់ការនានាគ្រប់ពេលវេលា និងសម្រាប់គ្រប់ដៃគូ ទាំងក្នុងក្រសួងផ្ទាល់ ទាំងជាមួយអង្គទូត និងដៃគូខាងក្រៅ។

៧. យើងក៏បានរៀបចំឲ្យមានប្រព័ន្ធពត៌មានវិទ្យាមួយដែលល្អប្រសើរ និងបានរៀបចំរចនាគេហទំព័រ (Website) របស់ក្រសួងដែលទាន់សម័យ និងមានផ្ទុកព័ត៌មានសម្បូរបែប។ ទន្ទឹមនោះ ក្រុមការងារប្រព័ន្ធបណ្តាញសង្គម (Facebook) របស់ក្រសួងបានរៀបចំបង្ហោះព័ត៌មានពីសកម្មភាពថ្នាក់ដឹកនាំ និងសេចក្តីប្រកាសសេចក្តីថ្លែងការណ៍នានាជាប្រចាំ ដែលជាប្រភពព័ត៌មានដ៏សំខាន់សម្រាប់ទាំងអង្គទូត ទាំងសារព័ត៌មាន និងមហាជនទូទៅ។

៨. <u>**ពិតហើយ បន្ទាត់នយោបាយគឺជាផ្នែកដ៏សំខាន់បំផុត។**</u> ចាំបាច់ណាស់ដែលត្រូវផ្តល់ជូនអ្នកការទូតរបស់យើង នូវគោលនយោបាយការបរទេស និងគោលដៅដ៏ច្បាស់លាស់មួយ ជាមាគ៌ាបង្ហាញទិស។ ថ្វីត្បិតយើងមិនទាន់បានចងក្រងជាសៀវភៅ ស្តីពីនយោបាយការបរទេសរបស់កម្ពុជាដែលការនេះទាមទារពេលវេលា ការស្រាវជ្រាវ សិក្សាពិចារណា និងការសម្របសម្រួលខ្ពស់នោះក្តី ក៏ប៉ុន្តែយើងបានរៀបចំតាក់តែងនូវការងារធំៗ ៥យ៉ាងដែលយើងបានបំពេញបន្ថែម កែលំអ និងសម្របតាមកាលៈទេសៈបត់បែនតាំងពីឆ្នាំ<u>២០១៧</u>មក ហើយដែលត្រូវបានលើកទឹកចិត្ត និងគាំទ្រដោយ **សម្តេចតេជោ** ទុកជាមគ្គុទ្ទេស នៃការងារការទូតរបស់យើង។

៩. <u>**ការងារធំៗទាំង ៥ នោះ មាន៖**</u>

(១) ការការពារផលប្រយោជន៍គោលរបស់ជាតិ ជាពិសេសការការពារឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី និងកិត្យានុភាពរបស់កម្ពុជា;

(២) ការអនុវត្តគោលនយោបាយការបរទេសឯករាជ្យផ្អែកលើច្បាប់អន្តរជាតិ ប្រកបដោយភាពបត់បែន វាងវៃ ឆ្លើយតបទៅនឹងសម្ពាធភូមិសាស្ត្រនយោបាយដ៏តានតឹងស្មុគ្រស្មាញ;

(៣) ការចូលរួមជាមួយសហគមន៍អន្តរជាតិ ក្នុងបុព្វហេតុសន្តិភាព ស្ថិរភាព មនុស្សធម៌ និងចូលរួមដោះស្រាយបញ្ហាប្រឈមនានានៅក្នុងពិភពលោក;

(៤) ការអនុវត្តការងារការទូតសេដ្ឋកិច្ច វប្បធម៌ និងទេសចរណ៍ ដើម្បីរួមចំណែកលើកស្ទួយសេដ្ឋកិច្ច; និង

(៥) ការបន្តការដ្ឋានកំណែទម្រង់ស្ថាប័ននៅក្នុងក្រសួង ដើម្បីរៀបចំអង្គអ្នកការទូតប្រកបដោយវិជ្ជាជីវៈ សកម្ម មានសមត្ថភាព និងស្នេហាជាតិ។

១០. ជារួម យើងបានការពារយ៉ាងគត់មុតនូវ ឯករាជ្យ និងអធិបតេយ្យជាតិ តបនឹងការប៉ុនប៉ងជ្រៀតជ្រែកចូលកិច្ចការផ្ទៃក្នុងរបស់យើង ការពារបូរណភាពទឹកដី តាមរយៈការការពារ និងចរចាយ៉ាងស្វិតស្វាញ ដើម្បីការពារដែនដីរបស់យើង ការពារយុត្តិធម៌ កិត្តិយស កេរ្តិ៍ឈ្មោះរបស់យើង នៅគ្រប់វេទិកា និងទីកន្លែងណាដែលត្រូវពួកអមិត្តបំភ្លៃ និងវាយប្រហារ។ យើងបានជំរុញ និងបង្កើនសកម្មភាពការទូតរបស់យើងនៅក្រៅប្រទេស ដោយបើកឡើងវិញ និងបង្កើតស្ថានទូតថ្មី ស្តារឡើងវិញនូវទំនាក់ទំនងជាមួយមិត្តចាស់ ពង្រីកទំនាក់ទំនង ជាមួយមិត្តថ្មី តាមរយៈបង្កើតយន្តការពិគ្រោះយោបល់ និងនយោបាយទ្វេភាគី ការធ្វើទស្សនកិច្ចផ្លូវការ និងការចូលរួមកិច្ចប្រជុំអន្តរជាតិនានារបស់រដ្ឋមន្ត្រីការបរទេស ក៏ដូចជា**សម្តេចតេជោ** និងថ្នាក់ដឹកនាំជាតិយើងនៅប្រទេសជាច្រើន។ យើងបានទទួលជោគជ័យក្នុងការធ្វើឲ្យតួនាទី និងការចូលរួមរបស់កម្ពុជាមានសារសំខាន់ក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ ដែលអ្នកផងទទួលស្គាល់ តួយ៉ាងជោគជ័យនៃការធ្វើម្ចាស់ផ្ទះកិច្ចប្រជុំកំពូលអាស៊ី-អឺរ៉ុប (ASEM) លើកទី១៣ ការធ្វើប្រធានអាស៊ានឆ្នាំ២០២២ កន្លងទៅ និងការបង្ហាញយ៉ាងជាក់ច្បាស់ពីជំហរកម្ពុជាផ្អែកលើច្បាប់អន្តរជាតិ ក្នុងបញ្ហាតំបន់ និងអន្តរជាតិ។

១១. ក្នុងក្របខណ្ឌទ្វេភាគីក្តី ពហុភាគីក្តី យើងបានផ្តល់នូវការគាំទ្រ និងកិច្ចសហប្រតិបត្តិការ ដែលមានផលប្រយោជន៍ទៅវិញទៅមក បង្ហាញនូវសាមគ្គីភាព

រួមវិភាគទានឥតសំចៃដល់ផ្នែកមនុស្សធម៌ និងសន្តិភាព មានការជួយសង្គ្រោះអ្នកដំណើរលើនាវា Westerdam ការផ្តល់វ៉ាក់សាំងកូវីដ-១៩ ដល់ប្រទេសជិតខាងជាច្រើន និងវត្តមានកងទ័ពមួកខៀវរបស់យើង នៅទ្វីបអាហ្វ្រិក និងតំបន់មជ្ឈិមបូព៌ា ជាឧទាហរណ៍ស្រាប់។

១២. «យុទ្ធសាស្ត្រការទូតសេដ្ឋកិច្ច ឆ្នាំ២០២១-២០២៣» របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានដាក់ឱ្យអនុវត្តកាលពីខែមករា ឆ្នាំ២០២១ ក្នុងគោលបំណងរួមចំណែក៖

១) ជម្រុញពាណិជ្ជកម្មអន្តរជាតិ

២) ទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស

៣) លើកកម្ពស់វិស័យទេសចរណ៍ និង

៤) ជម្រុញការផ្លាស់ប្តូរវប្បធម៌ និងកីឡា។

ស្តែងចេញពីការងារខាងលើនេះ សៀវភៅម្ហូប «កេរដំណែលស្នាដៃម្ហូបខ្មែរ» (The Taste of Angkor) ដែលរៀបរៀងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ត្រូវបានទទួលជ័យលាភីធំៗចំនួន ៣ រួមមាន៖ ពានរង្វាន់ «សៀវភៅម្ហូបអាស៊ីដ៏ល្អដាច់គេ» (Best Asian Cuisine Book) ២ឆ្នាំជាប់គ្នា (២០២១ និង ២០២២) និង ពានរង្វាន់ «សៀវភៅម្ហូបឆ្នើមដែលរៀបរៀងដោយថ្នាក់ដឹកនាំនៃរដ្ឋ» (Heads of State/Food) (ឆ្នាំ២០២២) ពី Gourmand World Cookbook Awards។ ក្នុងន័យនេះ ខ្ញុំជឿជាក់យ៉ាងមុតមាំថា ដោយសារឯកឧត្តមឧបនាយករដ្ឋមន្ត្រីមានសមត្ថភាព និងបទពិសោធន៍ដ៏សម្បូរបែបខាងវិស័យសេដ្ឋកិច្ច និងវិនិយោគនោះ ឯកឧត្តមនឹងបន្តជម្រុញសកម្មភាពនានានៃយុទ្ធសាស្ត្រការទូតសេដ្ឋកិច្ចឈានទៅកាន់កម្រិតថ្មីកាន់តែខ្ពស់ថែមទៀតមិនខាន។

១៣. បើប្រសិនជាសមិទ្ធផលខាងលើអាចជារង្វាស់នៃការបំពេញបេសកកម្មការទូត របស់យើងបាន នោះខ្ញុំអាចនិយាយបានថា ខ្ញុំបំពេញភារកិច្ចនេះបានសម្រេច។ លើសពីនេះ ខ្ញុំត្រូវនិយាយថា យើងទាំងអស់គ្នាបានបំពេញបេសកកម្មនេះ ដោយជោគជ័យ ពីព្រោះនេះជាលទ្ធផល ជាសមិទ្ធផល ដែលកើតចេញពី ឆន្ទៈរួម ការប្រឹងប្រែងរួម ដើម្បីផលប្រយោជន៍រួម។ ចាប់ពីចូលកាន់តំណែង នាថ្ងៃទី១ ខ្ញុំបានស្នើសុំការគាំទ្ររបស់ថ្នាក់ដឹកនាំ មន្ត្រី បុគ្គលិកទាំងអស់ ដើម្បីសម្រេចភារកិច្ចរួមរបស់ក្រសួងយើង។ ខ្ញុំអរគុណខ្លាំងណាស់ ដែលអ្នក ទាំងអស់គ្នាបានផ្តល់នូវការគាំទ្រនេះដោយឥតសំចៃ។

**ឯកឧត្តម លោកជំទាវ**
**អស់លោក លោកស្រី,**

១៤. ពិភពលោកសព្វថ្ងៃបានវិវត្តន៍មកកាន់ស្ថានភាពមួយខុសឆ្ងាយពីជាង ៧ឆ្នាំ មុន។ ជម្ងឺរាលដាលកូវីដ-១៩ មានចំណែកដ៏ធំមួយក្នុងការផ្លាស់ប្តូរស្ថានភាព នេះ រុញល្បឿនវិបត្តិ និងភាពតានតឹងនានាដែលមានស្រាប់ ធ្វើឲ្យការប្រកួត ប្រជែងដ៏ស្រួចស្រាល រវាងមហាអំណាចធំបំផុតក្នុងលោក កាន់តែធ្ងន់ធ្ងរ។ ការប្រកួតប្រជែងនេះបានអូសទាញមហាអំណាចផ្សេងទៀតចូលក្នុងការ បង្កើតជាប្លុក សម្ព័ន្ធភាពតូចៗ នាំទៅដល់ការធ្វើនយោបាយតូបនីយកម្ម និងសន្តិសុខនីយកម្ម នៃយន្តការតំបន់ និងអនុតំបន់ដែលមានគោលដៅ ដើមខាងសេដ្ឋកិច្ច សង្គម និងវប្បធម៌។ វិបត្តិ និងសង្គ្រាមថ្មីបានកកើតឡើង ហើយអូសបន្លាយដល់បច្ចុប្បន្ន។

១៥. នៅក្បែរយើង គឺវិបត្តិមីយ៉ាន់ម៉ា ដែលកម្ពុជាយើង ជាពិសេស **សម្តេចតេជោ** និងខ្លួនខ្ញុំផ្ទាល់ក្នុងឋានៈជាប្រេសិតពិសេសរបស់ប្រធានអាស៊ាន បានខិតខំ ប្រឹងប្រែងរកច្រកចេញ និងនាំប្រទេសនេះមកកាន់ប្រក្រតីភាពវិញ។ ឧបទ្វីប កូរ៉េ ច្រកសមុទ្រតៃវ៉ាន់ សមុទ្រចិនខាងកើត និងខាងត្បូង នៅតែជាក្នក់នៃ

ភាពតានតឹង ដែលប្រកបដោយភាពផុយស្រួយ និងគ្រោះថ្នាក់សម្រាប់សន្តិភាព និងស្ថិរភាពតំបន់។

១៦. ស្ថិតនៅឯនាយខាងភូមិសាស្ត្រ ប៉ុន្តែជិតបង្កើយដោយសារផលប៉ះពាល់អវិជ្ជមាន និងភាពស្មុគ្រស្មាញ ដែលវិបត្តិនេះបង្កឡើងក្នុងទំនាក់ទំនងអន្តរជាតិ គឺសង្គ្រាមនៅអ៊ុយក្រែន។ វិបត្តិ និងភាពតានតឹងនានាផ្សេងទៀតនៅតំបន់ជាច្រើនក្នុងលោក ក៏កំពុងបង្វែរធនធានដែលត្រូវការបំផុតឲ្យចេញចាកឆ្ងាយពីកង្វល់ និងការយកចិត្តទុកដាក់របស់យើង សម្រាប់ភាពប្រសើររបស់មនុស្សជាតិ ជួយប្រទេសក្រីក្រ ទប់ស្កាត់ផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃការប្រែប្រួលអាកាសធាតុ និងប្រយុទ្ធប្រឆាំងការរត់ពន្ធខុសច្បាប់គ្រប់ប្រភេទ និងនិយាយដោយខ្លី គឺសង្គ្រោះភពផែនដីរបស់យើង។

១៧.«My dear successor, my friend! ខ្ញុំគ្មានចេតនាណាឡើយក្នុងការផ្ទេរស្ថានភាពពិភពលោកដ៏ស្មុគ្រស្មាញ ពិបាកប៉ាន់ស្មាន ប្រែប្រួលឆាប់រហ័ស និងប្រកបដោយគ្រោះថ្នាក់នេះ ជូនឯកឧត្តម នោះឡើយ។ ហើយក៏មិនមែនជាកំហុសប្រទេសតូចមួយដូចកម្ពុជានោះទេ ដែលពិភពលោកបានធ្លាក់ក្នុងស្ថានភាពមួយ ដែលមនុស្សជាច្រើនប្រៀបប្រដូចទៅនឹងសម័យកាលសង្គ្រាមត្រជាក់នោះ ព្រោះយើងជាអ្នករងផលប៉ះពាល់ មិនមែនជាអ្នកបង្កើតនូវស្ថានភាពនោះឡើយ។ ប៉ុន្តែ វាជាភារកិច្ច ជាកាតព្វកិច្ចរបស់យើងក្នុងការកាច់ចង្កូតនាវាកម្ពុជាយ៉ាងណា ឲ្យឆ្លងផុតព្យុះព្យោមាទាំងនោះដោយសុវត្ថិភាព។

១៨. យើងមានបន្ទាត់ធំៗនៃនយោបាយការបរទេសរបស់យើងហើយ ប៉ុន្តែធនធាន និងមធ្យោបាយ ដើម្បីអនុវត្តគោលនយោបាយនោះដោយប្រសិទ្ធិភាព មិនទាន់ឆ្លើយតបនឹងតម្រូវការចាំបាច់នៅឡើយ។ ក្រសួងយើងសម្បូរទៅដោយថ្នាក់ដឹកនាំ មន្ត្រីជើងចាស់ដ៏មានបទពិសោធន៍ មន្ត្រីវ័យក្មេងពូកែៗ ដែលបានរៀនសូត្រជ្រៅជ្រះ និងប្រកបដោយឆន្ទៈ និងថាមពល។ **សម្តេចតេជោ** បានគាំទ្រដល់សំណើបង្កើនចំនួន និងលើកទឹកចិត្តដល់មន្ត្រីការទូត។ ប៉ុន្តែយើងត្រូវការពេលវេលាច្រើន និងមធ្យោបាយគ្រប់គ្រាន់ ដើម្បីប្រែក្លាយមន្ត្រី

វ័យក្មេងទាំងនោះ ឲ្យទៅជាអ្នកការទូតដ៏ប៉ិនប្រសព្វ មានវិជ្ជាជីវៈខ្ពស់ និង ជាយុទ្ធជនដ៏មុតស្រួច ក្នុងការការពារផលប្រយោជន៍គោលរបស់ជាតិ ប្រកបដោយស្វាមីភក្តិ និងមនសិការស្នេហាជាតិ។

១៩. យើងបានឆ្លងផុតជាមួយគ្នានូវឧបសគ្គ ការប្រឈមធំៗ និងអបអរជាមួយគ្នា នូវជោគជ័យទាំងនោះបាន ក៏ដោយសារមានការគាំទ្រ ការលើកទឹកចិត្ត ការ ចង្អុលផ្លូវ និងចង្អុលទិស ប្រកបដោយភាពវៀងវៃ និងកិត្តិបណ្ឌិតពី **សម្តេច អគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលជាប្រមុខការទូតដ៏កំពូលផុតគេ ក្នុងប្រវត្តិសាស្ត្រខ្មែរ។ អនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចតេជោ** ក្នុងការ « **កែទម្រង់ផ្ទៃក្នុង បង្កើនមិត្តខាងក្រៅ ដោយឈរលើស្មារតីឯករាជ្យ**» និងជំហរ **«អនុវត្តនយោបាយការបរទេសឯករាជ្យ ផ្អែកលើច្បាប់អន្តរជាតិ»** (ពិសេស នៅក្នុងសង្គ្រាមនៅអ៊ុយក្រែន) គឺជាប្រទីបបំភ្លឺផ្លូវការងារការទូតដ៏ឥត ខ្ចោះ។ ការដឹងគុណ និងការគោរពដ៏ជ្រាលជ្រៅបំផុតរបស់យើងទាំងអស់គ្នា ចំពោះ**សម្តេចតេជោ** នឹងស្ថិតនៅជានិច្ចក្នុងបេះដូងរបស់យើង។

២០. សម្រាប់រូបខ្ញុំ ការធ្វើដំណើររួមគ្នាក្នុងក្រសួងការបរទេសយើង បានដល់ទី បញ្ចប់នៅថ្ងៃនេះ។ ប៉ុន្តែ សម្រាប់អ្នកទាំងអស់គ្នាជាថ្នាក់ដឹកនាំ និងមន្ត្រី ការទូតទាំងអស់ ដំណើរបេសកកម្មនេះ នៅបន្តទៅមុខ លើផ្លូវដ៏លំបាកតែ ថ្លៃថ្នូរបំផុត។ នាឱកាសចុងក្រោយនេះ ខ្ញុំសូមប្រសិទ្ធិពរជ័យសិរីសួស្តីមហា ប្រសើរបំផុត ជូនចំពោះសហការី មិត្តជាទីស្រលាញ់ទាំងអស់ សូមទទួល បានជោគជ័យថ្មីៗថែមទៀត ក្នុងការងារ និងសុភមង្គល វិបុលសុខ ក្នុងគ្រួ សារ។

២១. បេសកកម្មរបស់អ្នកទាំងអស់ នឹងត្រូវដឹកនាំដោយមេថ្មី, my successor and my friend! ខ្ញុំសូមអបអរសាទរជាថ្មីម្តងទៀតដល់ **ឯកឧត្តម សុខ ចិន្តាសោភា** ដែលត្រូវបានទទួលទំនុកចិត្តដ៏ខ្ពង់ខ្ពស់មកកាន់តំណែងនេះ និងសូមជូនពរ ឯកឧត្តម សូមទទួលបានជោគជ័យមហាប្រសើរបំផុតក្នុងបេសកកម្មដ៏ ថ្លៃថ្នូរនេះ។ ខ្ញុំក៏សូមឆ្លៀតឱកាសដ៏ឱឡារិកនេះសូមជូនពរដល់**ឯកឧត្តមកិត្តិ**

**ទេសាភិបាលបណ្ឌិត ហ៊ុន ម៉ាណែត** ព្រមទាំងគណៈរដ្ឋមន្ត្រីថ្មីសូមសម្រេចបានជោគជ័យក្នុងបេសកកម្មដ៏ឧត្តុង្គឧត្តមដឹកនាំនាវាកម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍ និងរីកចម្រើនបន្ថែមទៀតលើគ្រប់វិស័យ។

សូមអរគុណចំពោះការគាំទ្រ និងមិត្តភាព ដែលអ្នកទាំងអស់គ្នាបានផ្តល់មកខ្ញុំ និងចំពោះអនុស្សាវរីយ៍ដែលយើងបានកសាងជាមួយ។

-----